**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីថ្លែងការណ៍ព្រះរាជាណាចក្រកម្ពុជា ក្នុងកិច្ចប្រជុំជាន់ខ្ពស់ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ នៃមហាសន្និបាតអង្គការសហប្រជាជាតិ

## ថ្ងៃទី៨-១០ ខែមិថុនា ឆ្នាំ២០២១ តាមបណ្តាញវីដេអូ

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមអបអរសាទរមហាសន្និបាតដែលនឹងអនុម័តសេចក្តីប្រកាសនយោបាយស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ក្រោមប្រធានបទ *"ការបញ្ចប់វិសមភាព និងការឈានទៅរកការបញ្ចប់ជំងឺអេដស៍ នៅឆ្នាំ២០៣០"*។ មកដល់របត់ប្រវត្តិសាស្ត្រពិភពលោកដ៏សំខាន់នេះ ប្រទេសកម្ពុជានៅតែប្តេជ្ញាថានឹងសម្រេចគោលដៅ៩៥-៩៥-៩៥ ឱ្យបាននៅឆ្នាំ២០២៥។

ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន៧នៅលើសកលលោក ដែលបានសម្រេចគោលដៅ៩០-៩០-៩០ ក្នុងឆ្នាំ២០១៧។ សមិទ្ធផលទាំងនេះបានសម្រេចឡើង ដោយមានការសម្របសម្រួលល្អរវាងស្ថាប័នរដ្ឋ ពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល តំណាងបណ្តាញអ្នកផ្ទុកមេរោគអេដស៍ ប្រជាជនគន្លឹះ និងងាយរងគ្រោះនៅទូទាំងប្រទេស។

ផ្អែកលើការនិទស្សន៍ ប្រទេសកម្ពុជានឹងមិនអាចកាត់បន្ថយករណីឆ្លងថ្មី តាមគោលដៅនៅឆ្នាំ២០២៥បានឡើយ។ កង្វះមូលនិធិក្នុងការបង្ការមេរោគអេដស៍ ជាឧបសគ្គរារាំងដល់ការពង្រីកអន្តរាគមន៍ប្រកបដោយភាពច្នៃប្រឌិត ដើម្បីជួយដល់យុវជនដែលមានការប្រឈមខ្ពស់ ជាពិសេសក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ។

នៅប្រទេសកម្ពុជា ផលប៉ះពាល់នៃការរាតត្បាតជំងឺកូវីដ-១៩ បានកាត់បន្ថយលទ្ធភាពនៃការឆ្លើយតបនឹងជំងឺអេដស៍។ ការរាតត្បាតនេះបានបង្កជាគ្រោះថ្នាក់ដល់ការវិនិយោគផ្នែកសុខភាពសាធារណៈ ដែលរួមមានការពង្រឹងប្រព័ន្ធសុខាភិបាល និងការត្រៀមប្រយុទ្ធនឹងជំងឺរាតត្បាតនានា។

នៅលើផែនទីបង្ហាញផ្លូវរបស់យើងឆ្ពោះទៅចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្រសួងនិងស្ថាប័នពាក់ព័ន្ធមួយចំនួនបានខិតខំប្រឹងប្រែងអនុវត្ត វិធានការ៦ចំណុចដែលមានចែងក្នុង សេចក្តីជូនដំណឹងលេខ ២១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានដាក់ចេញនៅដើមឆ្នាំ២០១៩។ វិធានការទាំងនេះអាចចាត់ទុកជាប្លង់គោលសម្រាប់ចង្អុលទិសសកម្មភាពទាំងនៅក្នុងវិស័យសុខាភិបាល និងវិស័យពាក់ព័ន្ធនានាដើម្បីគាំទ្រដល់ចលនាជាតិពីថ្នាក់កណ្តាលដល់ថ្នាក់មូលដ្ឋានដោយផ្តោតលើ ការពង្រឹងរចនាសម្ព័ន្ធ

ជាតិក្នុងភាពជាដៃគូជិតស្និទ្ធជាមួយបណ្តាញសហគមន៍ សំដៅដោះស្រាយដើមហេតុនៃវិសមភាពក្នុងការទទួលបានសេវាសាធារណៈ។

ស្របតាមគោលការណ៍ដែល *"មិនទុកនរណាម្នាក់ចោល"* យើងប្តេជ្ញាអនុវត្តអភិក្រមដែលផ្តោតលើការយកប្រជាពលរដ្ឋជាគោល និងដែលអាចបញ្ជ្រាបការឆ្លើយតបនឹងជំងឺអេដស៍។ នេះមានន័យថា គោលនយោបាយ និងកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជាការធានាវិសាលភាពគ្របដណ្តប់សុខភាពសកល ការគាំពារសង្គម និងកិច្ចខិតខំប្រឹងប្រែងដទៃទៀតដែលសំដៅសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ក៏ត្រូវមានបញ្ជ្រាបការឆ្លើយតបនឹងជំងឺអេដស៍ផងដែរ។

ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ប្រទេសកម្ពុជាប្តេជ្ញាចាត់វិធានការបន្ទាន់តាមរយៈការឆ្លើយតបរបស់ជាតិដែលមានការសម្របសម្រួលដោយផ្អែកលើសាមគ្គីភាពជាសកល និងការទទួលខុសត្រូវរួមគ្នា ដើម្បីអនុវត្តការប្តេជ្ញាចិត្តធ្វើឱ្យសម្រេចគោលដៅ និងគោលបំណងដែលមានចែងនៅក្នុងសេចក្តីប្រកាសនយោបាយនេះ។

ជាទីបញ្ចប់ ជាមួយនឹងការប្តេជ្ញាចិត្តរបស់យើងក្នុងការផ្លាស់ប្តូរពីការពឹងផ្អែកទៅលើជំនួយពីខាងក្រៅប្រទេសទៅជាការពឹងផ្អែកលើធនធានក្នុងស្រុក យើងខ្ញុំសូមសម្តែងការព្រួយបារម្ភចំពោះផលប៉ះពាល់នៃការរាលដាលជំងឺកូវីដ-១៩។ ទាក់ទងនឹងបញ្ហានេះ ខ្ញុំសូមអំពាវនាវដល់ប្រទេសអភិវឌ្ឍន៍ទាំងឡាយសូមមេត្តាពិចារណាអំពីជំនួយអភិវឌ្ឍន៍ក្រៅប្រទេស និងគណនាទំហំនៃកិច្ចឧបត្ថម្ភឡើងវិញ ដើម្បីឱ្យសមស្របទៅនឹងស្ថានភាពប្រទេស និងរក្សាបាននូវលទ្ធផលនៃការឆ្លើយតបពីមុនរបស់យើង ហើយអាចបិទគម្លាតដែលរារាំងដល់ការរីកចម្រើនឆ្ពោះទៅរកការបញ្ចប់ជំងឺអេដស៍។

សូមអរគុណ។